រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

044KH01A-01

របៀបដែលក្រុមតូច
អាចជួយក្រុមជំនុំរបស់អ្នក



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៤៤

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

សូមអាន សេរីភាព ១៨:១៣-២៧ ។



ប្រជាជនអ៊ីស្រាអែលមានចំនួនច្រើនពាន់នាក់ ហើយលោកម៉ូសេ
ខិតខំដោះស្រាយបញ្ហារបស់ប្រជាជនម្នាក់ៗដោយផ្ទាល់ ។



កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

ឪពុកក្មេករបស់លោកម៉ូសេផ្តល់យោបល់ដល់លោកម៉ូសេ...



លោកយេត្រូពន្យល់លោកម៉ូសេថា បើសិនជាលោកម៉ូសេនៅតែបន្តដោះស្រាយបញ្ហារបស់ប្រជាជនម្នាក់ៗ ដោយខ្លួនឯងតទៅទៀត ទាំងលោកម៉ូសេខ្លួនឯង ទាំងប្រជាជន នឹងនឿយហត់ខ្លាំងណាស់ ។ លោកយេត្រូអោយយោបល់ថា ត្រូវចែកបណ្តាជនជាក្រុម ហើយក្រុមនិមួយៗត្រូវមានមេក្រុម និង ចៅក្រមរបស់ខ្លួន ។

លោកម៉ូសេក៏ធ្វើតាមដំបូន្មានដ៏ឈ្លាសវៃនេះ ដែលមានប្រយោជន៍ទាំងចំពោះលោក ទាំងចំពោះបណ្តាជន ។



ស្ថានភាពដែលលោកម៉ូសេជួបប្រទះនេះ តែងតែកើតមានចំពោះគ្រប់ក្រុមមនុស្ស ដែលចេះតែរីកធំឡើងៗ ។ ក្រុមនឹងរីកធំដល់កំរិតមួយ ដែលមនុស្សតែម្នាក់ មិនអាចដោះស្រាយគ្រប់កិច្ចការបានឡើយ ។ បើសិនជាអ្នកដឹកនាំ មិនបែងចែកភារៈកិច្ចរបស់ខ្លួនអោយអ្នកផ្សេងជួយបំពេញទេនោះ ការងារនឹងមិនរីកចំរើនទៅមុខ ហើយអ្នកដឹកនាំខ្លួនឯងនឹងនឿយហត់ខ្លាំង ទាំងខាងរូបកាយ ខាងគំនិតប្រាជ្ញា និង ខាងព្រលឹងវិញ្ញាណ ដោយសារតែធ្វើការហួសកម្លាំង ។

កិច្ចការដែលត្រូវអនុវត្ត

- មើលឡើងវិញពីសេចក្តីទាំងប៉ុន្មាន ដែលអ្នកបានគូសសញ្ញាសំគាល់ «✓»នេះ នៅពេលអ្នកបានសិក្សាសៀវភៅនេះ ហើយយកសេចក្តីទាំងនេះទៅអនុវត្ត ដើម្បីបង្កើតក្រុមតូចនៃក្រុមជំនុំ និង កសាងក្រុមទាំងនោះអោយរីកចំរើនឡើង ។
- ទូលសូមអោយព្រះជាម្ចាស់ដឹកនាំ និង សរសេរផែនការរបស់អ្នកនៅក្នុងចន្លោះខាងក្រោមនេះ ។

© Project WorldReach © SEAN

៥- គួសសញ្ញាសំគាល់កិច្ចការដែលមិនត្រូវធ្វើនៅក្នុងក្រុមតូច :

☐ បំរើភេសជ្ជៈរាល់ពេលប្រជុំ ។

☐ អញ្ជើញអ្នកណាក៏បានអោយមកអធិប្បាយ ។

☐ និយាយអំពីរឿងខាងជំនួញផ្ទាល់ខ្លួន ។

៦- តើក្រុមត្រូវជួបប្រជុំគ្នានៅឯណា ?

☐ នៅផ្ទះអ្នកជីកនាំ ។

☐ នៅផ្ទះសមាជិកម្នាក់ ឬ មិត្តភក្តិម្នាក់ ។

បើមានសមាជិកច្រើនពេក នៅក្នុងក្រុមជំនុំ ឬ ក្រុមជំនុំតាមផ្ទះ សមាជិកនឹងទទួលបានការមើលថែពីគ្រូគង្វាល កាន់តែតិចទៅៗ ។

ហេតុនេះហើយបានជាយើងត្រូវគ្រប់គ្រងក្រុមជំនុំ តាមរយៈក្រុមតូច ។

(សូមគួសសញ្ញា «✓» នេះ នៅនឹងសេចក្តីត្រូវការរបស់ក្រុមជំនុំអ្នក) ក្រុមតូចនេះនឹងជួយបំពេញ :

☐ **កិច្ចការឃ្វាល** : ពីព្រោះនៅក្នុងក្រុមតូច សមាជិកអាចទទួលបានការមើលថែ ដោយផ្ទាល់ច្រើនជាង ។

☐ **ការផ្សាយដំណឹងល្អ** : ពីព្រោះសមាជិកដែលនៅក្នុងក្រុមតូចផ្សាយដំណឹងល្អ និង ទទួលសមាជិកថ្មីអោយចូលរួមក្នុងក្រុមតូចនោះ ងាយជាងក្រុមជំនុំធំ ដែលមានសមាជិកច្រើន ។

☐ **ការបង្រៀន** : ពីព្រោះនៅក្នុងក្រុមតូច សមាជិកទាំងអស់អាចចូលរួមចំណែកក្នុងការសិក្សា មិនមែនគ្រាន់តែស្តាប់សេចក្តីអធិប្បាយដូចនៅក្នុងក្រុមជំនុំធំទេ ។

☐ **ការបង្ហាត់បង្រៀនអ្នកបំពេញកិច្ចការឃ្វាលថ្មី** : ពីព្រោះយើងអាចបង្ហាត់បង្រៀន និង ពិនិត្យមើលពួកអ្នកដឹកនាំថ្មីប្រកបដោយប្រសិទ្ធិភាពជាង នៅក្នុងក្រុមតូច ។



☐ កសាងគ្នាទៅវិញទៅមក (១ ថែស្សាឡូនិក ៥:១១) ។

☐ ជាស់តឿនអោយស្តាប់បង្គាប់ព្រះជាម្ចាស់ (ហេប្រឺ ៣:១៣) ។

☐ អធិស្ឋានសំរាប់គ្នាទៅវិញទៅមក (យ៉ាកុប ៥:១៦) ។

☐ នាំមិត្តភក្តិដែលមិនទាន់ជឿ ឱ្យមកចូលរួម (២ ធីម៉ូថេ ៤:៥) ។

៣- តើមុខងារបំរើជាមូលដ្ឋានរបស់ក្រុមតូច គឺអ្វី ?

☐ ស្តាប់អ្នកដឹកនាំអធិប្បាយ ។

☐ ផ្សព្វផ្សាយដំណឹងល្អ និង ជួយកសាងគ្នាទៅវិញទៅមកដោយសេចក្តីស្រឡាញ់ ។

៤- ការសិក្សាព្រះគម្ពីរក្នុងក្រុមតូច គឺ :

☐ ដូចទៅនឹងសេចក្តីអធិប្បាយ ឬ ដូចទៅនឹងថ្នាក់រៀនព្រះគម្ពីរនៅថ្ងៃអាទិត្យ ។

☐ ការសិក្សាព្រះគម្ពីរ ដែលសមាជិកម្នាក់ៗអាចចូលរួមពិភាក្សា និង ចែកចាយយោបល់ ។

© Project WorldReach © SEAN

អ្នកដឹកនាំក្រុមតូច ត្រូវមានលក្ខណៈពិសេសទាំងអស់នេះ ។ តើអ្នកត្រូវបង្កើនកិរិតលក្ខណៈពិសេសណាខ្លះ ? ។

_____

_____

_____

_____

២- គួសសញ្ញាសំគាល់ នៅក្បែរសកម្មភាពខាងក្រោមនេះខ្លះដែលសមាជិកក្រុមត្រូវអនុវត្តខ្លាំងជាងមុន :

- ☐ ស្រឡាញ់គ្នាទៅវិញទៅមក (យ៉ូហាន ១៥:១៧) ។
- ☐ បំរើអ្នកដទៃ (កាឡាទី ៥:១៣) ។
- ☐ ដាស់តឿនអោយធ្វើអំពើល្អ (ហេប្រឺ ១០:២៤) ។
- ☐ អត់ទោសដោយអំណត់ (កូឡូស ៣:១៣) ។
- ☐ កែតម្រូវដោយសេចក្តីស្រឡាញ់ (កូឡូស ៣:១៦) ។
- ☐ កំសាន្តចិត្តគ្នាទៅវិញទៅមក (១ ថេស្សាឡូនិក ៤:១៨) ។

លោកគ្រូ ! តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីនាំមនុស្សអោយជឿលើព្រះគ្រីស្តកាន់តែច្រើនឡើងៗ ? មួយខែមុន ខ្ញុំបានចែកចាយដំណឹងល្អប្រាប់មិត្តភក្តិខ្ញុំម្នាក់ឈ្មោះជុន ។ ពីម្សិលមិញ ជុនបានទទួលព្រះគ្រីស្តជាព្រះសង្រ្គោះរបស់គាត់ ។ ឃើញដូចនេះ ខ្ញុំមានចិត្តចង់នាំអ្នកឯទៀតឲ្យជឿលើព្រះអម្ចាស់ដែរ ។ តើខ្ញុំមានកម្មវិធីណា ដែលជួយអោយខ្ញុំអាចធ្វើកិច្ចការនេះបាន ?



ដើម្បីអោយមនុស្សជឿលើព្រះគ្រីស្ត កាន់តែច្រើនឡើងៗ ប្អូនត្រូវបង្រៀនជុនអោយក្លាយជាសាវ័ក ដើម្បីអោយគាត់អាចផ្សាយដំណឹងល្អប្រាប់ក្រុមគ្រួសារ និង មិត្តភក្តិរបស់គាត់ ។



ការប្រឡង (សំនួរសង្ខេបមេរៀន)

១- សូមគូសសញ្ញាសំគាល់នៅក្បែរលក្ខណៈពិសេស ដែលអ្នកដឹកនាំក្រុមតូចត្រូវមាន ដើម្បីអាចដឹកនាំក្រុមតូចរបស់ខ្លួន :

- ☐ បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ។
- ☐ អធិស្ឋានសំរាប់សមាជិកទាំងអស់របស់ក្រុមគាត់ ។
- ☐ មានទឹកចិត្តពុះកញ្ជ្រោល និង លើកទឹកចិត្តអ្នកដទៃ ។
- ☐ អោចទុកចិត្តបាន ចេះទទួលខុសត្រូវ និង ចេះគោរពពេលវេលា ។
- ☐ ចូលរួមក្នុងក្រុមជំនុំ ដោយទៀងទាត់ ។
- ☐ មានសេចក្តីស្រឡាញ់ជាក់ស្តែងចំពោះក្រុមគ្រួសាររបស់គាត់ និង មនុស្សឯទៀត ។
- ☐ ខំសិក្សា និង ពន្យល់ព្រះបន្ទូលព្រះជាម្ចាស់ឱ្យបានល្អ ។
- ☐ ជាក់ដង្ហាយដប់ភាគរយ ដោយអំណរ ។
- ☐ ចេះនាំសមាជិកឯទៀត ឱ្យជួយបំពេញកិច្ចការឃ្វាល ។
- ☐ ទៅសួរសុខទុក្ខសមាជិកក្រុមតូចរបស់គាត់ ។
- ☐ មិននិយាយដើមគេ ។

© Project WorldReach © SEAN

- បង្កើតសាវ័ក (ម៉ាថាយ ៤:១៨-២២, ២៨:១៨-២០, លូកា ៥:១-១១, យ៉ូហាន ១៥:៥-១៧) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល ទី ៧ «របៀបបង្កើតសាវ័ក » ។

ប្រធានបទផ្សេងៗទៀត សំរាប់សិក្សាក្នុងក្រុមតូច (សូមសរសេរប្រធានបទ ដែលអ្នកគិតឃើញ) :

លោកសុខបានពិភាក្សាអំពីការនេះជាមួយប្រពន្ធគាត់ រួចអ្នកទាំងពីរនាំគ្នាអធិស្ឋានទូលសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំ ។ នៅអាទិត្យបន្ទាប់ លោកសុខ និង ប្រពន្ធនាំគ្នាទៅលេងផ្ទះរបស់អ្នកជឿថ្មីឈ្មោះជុន ហើយពន្យល់គាត់ពីផែនការនេះ ។



ពួកគេបានមកជួបជុំគ្នាជាលើកទីមួយ ហើយលោកណារ៉េតបាន
នាំក្រុមគ្រួសាររបស់គាត់ទាំងមូលមកចូលរួមដែរ ។ ក្នុងរយៈពេល
មួយអាទិត្យនោះ ពួកគេបានទៅអញ្ជើញមនុស្សផ្សេងទៀត ហើយ
នៅពេលជួបជុំគ្នាលើកក្រោយ មានមនុស្សចាស់ប្រាំបីនាក់ទៀត
មកចូលរួមដែរ ។



លោកសុខបានទៅជួបលោកគ្រូគង្វាល ដោយទឹកចិត្តពុះពោរយ៉ាង
ខ្លាំង ។



- ស្រឡាញ់ព្រះជាម្ចាស់ និង មនុស្សឯទៀត (លូកា ១០:២៥-៣៧) អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ១៩ «ការស្រឡាញ់អ្នកជឿថ្មី» និង កូនសៀវភៅ ទី ២១ «អ្នកជិតខាងរបស់ខ្ញុំ» ។
- ចូលរួមធ្វើពិធីកាច់នំប៉័ង (ម៉ាថាយ ២៦:១៧-២៩) ។
- អធិស្ឋាន និង សិក្សាព្រះបន្ទូលព្រះជាម្ចាស់ទុកជាចំណីអាហារខាងព្រលឹងវិញ្ញាណ (ម៉ាថាយ ៤:៤, លូកា ១៨:៩-១៤) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៦ «ការអធិស្ឋានក្នុងគ្រួសារ» ។
- ចែកចាយ និង ថ្វាយដង្វាយ (ម៉ាថាយ ២៥:១៤-៤៦, លូកា ១២:១៣-២១, ១៨:១៨-២៥) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៣ «អ្នកធ្វើអំណោយដោយចិត្តអំណរ» និង កូនសៀវភៅ ទី ២៩ «ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុនសិន» ។

© Project WorldReach © SEAN

☐ បញ្ជូនគ្រីស្តទូតអោយទៅកន្លែង ដែលពិបាកចូលទៅផ្សាយដំណឹងល្អ (ម៉ាថាយ ២៨:១៨-២០, រ៉ូម ១៥:២០-២១, ២ កូរិនថូស ១០:១៤-១៦) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៥៥ « សៀវភៅសំរាប់គ្រីស្តទូត » ។

☐ របៀបណែនាំប្រមូលពួកអ្នកជឿថ្មី ឱ្យប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត ។ ចំពោះសមាជិកថ្មីរបស់ក្រុមជំនុំ ដំបូង ត្រូវឱ្យពួកគេសិក្សាអំពីដំណើររឿងរបស់ព្រះគម្ពីរ ដែលស្តីអំពីសេចក្តីបង្គាប់សំខាន់ៗរបស់ព្រះយេស៊ូសិន ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៧ « របៀបបង្កើតសាវ័ក » ។

ឧទាហរណ៍ :

- កែប្រែចិត្តគំនិត និង ជឿ (លូកា ២៤:១៣-៥៣, យ៉ូហាន ៣:១-២១) ។
- ទទួលពិធីជ្រមុជទឹក (ម៉ាថាយ ជំពូក ៣, កិច្ចការ ២:៣៧-៤២) ។

លោកគ្រូគង្វាលកត់កិច្ចការ ដែលសមាជិកក្រុមត្រូវធ្វើ អោយទៅលោកសុខ ។ សមាជិកក្រុមក៏អនុវត្តកិច្ចការទាំងនេះបន្តិចម្តងៗ ។



១- ពួកគេត្រូវស្រឡាញ់គ្នា (យ៉ូហាន ១៥:១៧) ។
២- ពួកគេត្រូវបំរើគ្នា (កាឡាទី ៥:១៣) ។
៣- ពួកគេត្រូវចេះដាស់តឿនគ្នាឱ្យធ្វើអំពើល្អ (ហេប្រឺ ១០:២៤) ។
៤- ពួកគេត្រូវអត់ទោសឱ្យគ្នាទៅវិញទៅមក ដោយអំណត់ (កូឡូស ៣:១៣) ។
៥- ពួកគេត្រូវកែតម្រូវ និង ដាស់តឿនគ្នាដោយសេចក្តីស្រឡាញ់ (កូឡូស ៣:១៦) ។
៦- ពួកគេត្រូវសំរាលទុក្ខគ្នាទៅវិញទៅមក (១ ថេស្សាឡូនិក ៤:១៨) ។
៧- ពួកគេត្រូវលើកទឹកចិត្ត និង អប់រំគ្នាទៅវិញទៅមក (១ ថេស្សាឡូនិក ៥:១១) ។
៨- ពួកគេត្រូវដាស់តឿនគ្នាទៅវិញទៅមកឱ្យប្រតិបត្តិតាមព្រះអម្ចាស់ (ហេប្រឺ ៣:១៣) ។
៩- ពួកគេត្រូវអធិស្ឋានឱ្យគ្នាទៅវិញទៅមក (យ៉ាកុប ៥:១៦) ។
១០- ពួកគេត្រូវនាំមិត្តភក្តិដែលមិនជឿអោយថ្វាយខ្លួន (២ ធីម៉ូថេ ៤:៥) ។

© Project WorldReach © SEAN

លោកគ្រូគង្វាលទៅសួរសុខទុក្ខលោកសុខ ដើម្បីលើកទឹកចិត្តគាត់ ហើយប្រាប់គាត់ថា÷



- ☐ ចិញ្ចឹមបីបាច់ថែរក្សាកូនចៅ ដើម្បីឱ្យពួកគេស្រឡាញ់ និងបំរើព្រះជាម្ចាស់ (ទុតិយកថា ៦:១-៩, សុភាសិត ២២:៦, ម៉ាកុស ១០:១៣-១៦, អេភេសូ ៦:១-៤, កូឡូស ៣:២០-២១) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៥៦ «គ្រួសាររបស់ខ្ញុំ» ។
- ☐ រៀបការ ដោយទុកចិត្តច្បាស់ថា អាចរស់នៅជាប្តីប្រពន្ធប្រកបដោយសុភមង្គល (កំណើតពិភពលោក ជំពូក ២៤, សុភាសិត ១៨:២២, ម៉ាកុស ១០:១-១២, ១ កូរិនថូស ជំពូក ៧, អេភេសូ ៥:២២-៣៣) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៥៦ «គ្រួសាររបស់ខ្ញុំ» ។
- ☐ ជួយសង្គមឱ្យអាចមានយុត្តិធម៌ ដោយសារសេចក្តីស្រឡាញ់ (សៀវភៅ អម៉ូស, សេរីភាព ២០:១-២៣:១៣, រ៉ូម ១៣:១-១៣, អេភេសូ ៦:៥-៩) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៣៦ «ក្រុម-ជំនុំ និង សង្គម» ។

© Project WorldReach © SEAN

- ☐ ត្រូវដឹងពីព្រះហឫទ័យព្រះជាម្ចាស់ ពេលត្រូវធ្វើការសំរេចចិត្ត (ទំនុកតម្កើង ៣២:៨, ១១៩:១០៥, សុភាសិត ៣:៥-៦, អេសាយ ២៦:៣-៤, រ៉ូម ៨:១៤) ។
- ☐ របៀបអធិស្ឋានដោយដឹងជាក់ថា ព្រះជាម្ចាស់បានឮសេចក្តីអធិស្ឋានរបស់យើង (ម៉ាថាយ ៦:៥-១៥, លូកា ១១:៥-១៣, ១៨:១-១៤) ។ អ្នកអាចប្រើក្លូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ១៣ «របៀបអធិស្ឋាន » ។
- ☐ ត្រូវដឹងពីអំណោយទាន និង បំពេញកិច្ចការបំរើតាមរយៈអំណោយទាននោះ (រ៉ូម ១២, ១ កូរិនថូស ជំពូក ១២-១៤, អេភេសូ ៤:១-១៦) ។ អ្នកអាចប្រើក្លូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៦០ «អំណោយទានខាងព្រលឹងវិញ្ញាណ » ។
- ☐ របៀបបណ្តុះអោយមានសេចក្តីសុខសាន្ត និង ភាពស្ងប់ស្ងៀមក្នុងក្រុមគ្រួសារ (១ កូរិនថូស ៧:១-១៧, អេភេសូ ៤:១៧-៣២, ១ ពេត្រុស ៣:១-៧) ។ អ្នកអាចប្រើក្លូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៥៦ «គ្រួសាររបស់ខ្ញុំ » ។

លោកសុខធ្វើតាមដំបូន្មានរបស់លោកគ្រូគង្វាលគាត់ ហើយគាត់សិក្សាបទគម្ពីរកិច្ចការចំពូក ទី ២ ឯក្រុមរបស់គាត់នៅតែបន្តជួបជុំគ្នាដូចមុន ។ សមាជិកក្រុមដាក់ឈ្មោះក្រុមនោះថា «កិច្ចការចំពូក ២» ពីព្រោះគោលដៅរបស់ពួកគេ គឺផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត ដោយពឹងផ្អែកលើទ្វានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។ មេគ្រួសារផ្សេងៗទៀតបានថ្វាយខ្លួន ហើយនាំក្រុមគ្រួសាររបស់ពួកគេមកចូលរួមក្នុងក្រុមសិក្សាព្រះគម្ពីរនេះដែរ ។



លោកសុខដែលជាអ្នកជីកនាំក្រុមតូច តែងតែទៅសួរសុខទុក្ខក្រុមគ្រួសារទាំងនោះ តាមផ្ទះរបស់ពួកគេដោយទៀងទាត់ ដើម្បីលើកទឹកចិត្តពួកគេ និង ជួយបំពេញសេចក្តីត្រូវការខាងព្រលឹងវិញ្ញាណរបស់ពួកគេ ។



លោកសុខក៏ទៅជួបលោកគ្រូគង្វាលរបស់គាត់រាល់អាទិត្យដែរ ដើម្បីឱ្យលោកគ្រូគង្វាលជួយរៀបចំផែនការ សំរាប់ការប្រជុំរបស់ក្រុមតូច ។ លោកសុខ និង លោកគ្រូគង្វាលអធិស្ឋានជាមួយគ្នា និង រៀបចំផែនការច្បាស់លាស់សំរាប់ក្រុមតូច ។



- ☐ ផ្តល់ដំបូន្មាន ដើម្បីសំរុះសំរួលអ្នកជឿ ដែលបាក់បែកគ្នា អោយជានានឹងគ្នាវិញ (ម៉ាថាយ ៥:២១-២៦, យ៉ូហាន ជំពូក ១៥-១៧, ១ កូរិនថូស ១:១០-១៦, ភីលីព ២:១-១១) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៣៩ « ការប្រដៅទូន្មាន ដោយសេចក្តីស្រឡាញ់ » ។
- ☐ ប្រៀនប្រដៅកែតម្រង់សមាជិករឹងចចេស និង គ្មានសណ្តាប់ធ្នាប់ ដោយមិនដាក់ទោស (ម៉ាថាយ ១៨:១៥-២២, កាឡាទី ៦:១) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៣៩ « ការប្រដៅទូន្មាន ដោយសេចក្តីស្រឡាញ់ » ។
- ☐ ត្រូវមានមនសិការជ្រះថ្លា និង សេចក្តីសុខសាន្តជាមួយព្រះជាម្ចាស់ (សិក្សាបន្តិចម្តងៗ រ៉ូម ៣:៩-៥:២១ និង ហេប្រឺ ៨:១-១០:២៥) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ៣៩ « ការប្រដៅទូន្មាន ដោយសេចក្តីស្រឡាញ់ » ។

© Project WorldReach © SEAN

ប្រធានបទខ្លះសំរាប់ការសិក្សាក្នុងក្រុមតូច

សូមគូសសញ្ញាសំគាល់ នៅក្បែរប្រធានបទដែលគួរយកមកសិក្សា :

☐ ដោះស្រាយទំនាស់នៅក្នុងក្រុមគ្រួសារ (អេភេសូ ៤:២៥-៣២, ៥:២១-៦:៤, ភីលីព ២:១-១១) ។

☐ ធ្វើគំរោងថវិកាគ្រួសារ ដើម្បីអាចត្រួតពិនិត្យមើលចំណូលចំណាយរបស់គ្រួសារកាន់តែប្រសើរ (លូកា ១៤:២៨, រ៉ូម ១៣:៥-៨, ភីលីព ៤:១១) ។

☐ បង្រៀនស្ត្រី និង បុរសអោយមានទំនាក់ទំនងល្អរវាងស្វាមី និង ភរិយា (សុភាសិត ៥:១-២៣, ១ កូរិនថូស ៧, អេភេសូ ៥:២២-៣៣, ១ ថេស្សាឡូនិក ៤:១-៨) ។

☐ ជួយជនរងគ្រោះ ដោយសារការប្រមឹកស្រា ការញៀនបារី ការញៀនគ្រឿងញៀន ។ល។ (ទំនុក. ៣៧:៥, សុភាសិត ១:៧, ២១:១៧, ២៣:២៩-៣៥, រ៉ូម ៥:៨, ៨:២៨, អេភេសូ ៥:១៨, ២ ធីម៉ូថេ ១:៧, ហេប្រឺ ១០:២៣-២៥, ១៣:៥-៨, ១ យ៉ូហាន ៤:១៨) ។ អ្នកអាចប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល ទី ៣៩ « ការប្រដៅទូន្មានដោយសេចក្តីស្រឡាញ់ » ។

គោលដៅនៃការផ្សាយដំណឹងល្អ
(សំរាប់ក្រុមរបស់លោកសុខ)

- ត្រូវទៅសួរសុខទុក្ខសាច់ញាតិ និង មិត្តជិតស្និទ្ធដែលនៅជិតខាង ។
- បន្ទាប់មក យើងត្រូវជួយមេគ្រួសារទាំងអស់ដែលបានថ្វាយខ្លួន អោយផ្សាយដំណឹងល្អប្រាប់ក្រុមគ្រួសាររបស់ខ្លួន ។
- ជួយសមាជិកក្នុងក្រុម « កិច្ចការ ចំពូក ២» អោយចេះដឹកនាំ ហើយត្រូវចាប់ផ្តើមបង្កើតក្រុមតូចថ្មីៗទៀត ។



© Project WorldReach © SEAN

គោលដៅនៃការបង្ហាត់បង្រៀន

- ជួយរៀបចំលោកជុនអោយក្លាយជាគ្រូជំនួយ ។
- ត្រូវអោយឪពុកម្តាយអានរឿងក្នុងព្រះគម្ពីរអោយកូនៗរបស់គេស្តាប់ជាទៀងទាត់ ហើយត្រូវអោយសមាជិកក្រុមគ្រួសារនិមួយៗអធិស្ឋានរៀងៗខ្លួន និង ជាមួយគ្រួសារទាំងមូលជារៀងរាល់ថ្ងៃ ។ ម៉្យាងទៀត ត្រូវរៀបចំលោកជុនអោយចេះដឹកនាំការសិក្សា និង ការពិភាក្សារបស់ក្រុមតូច ហើយនាំពួកអ្នកជឿថ្មីអោយទៅចូលរួមក្នុងការប្រជុំថ្វាយបង្គំ នៅក្នុងក្រុមជំនុំម្តាយ ។
- ដាក់ភារៈកិច្ចអោយលោកជុនបំពេញកាន់តែច្រើន រហូតដល់គាត់អាចដឹកនាំការងារគ្រប់យ៉ាងរបស់ក្រុមតូចបាន ។ បន្ទាប់មក គាត់អាចបង្កើតក្រុមថ្មីមួយទៀត ឬ បន្តជួយដឹកនាំក្រុមតូចដដែលនោះ ។

៤- ការសិក្សាព្រះគម្ពីរ

សិក្សាខគម្ពីរទាំងឡាយដែលទាក់ទងទៅនឹងជីវិត និង កិច្ចការបំរើរបស់សមាជិកក្រុម ។ ពិចារណាជាមួយគ្នាពីរបៀបដែលត្រូវប្រព្រឹត្តតាមគោលការណ៍របស់ព្រះបន្ទូលក្នុងជីវិត និង កិច្ចការបំរើរបស់ពួកគេ ។ (សិក្សាព្រះគម្ពីរតាមរបៀបមួយ ដែលឱ្យសមាជិកអាចចូលរួមបាន ដូចជាឆ្លើយសំណួរពិភាក្សាជាមួយគ្នា ផ្តល់យោបល់ ។ល។) ។

៥- គំរោងផែនការ

អ្នកដឹកនាំកត់គំរោងសំរាប់ការផ្សាយដំណឹងល្អ ឬ កិច្ចការបំរើផ្សេងទៀត ជូនសមាជិកម្នាក់ៗ ឬ ប្តីប្រពន្ធ ឬ ក្រុមគ្រួសារ ។ អ្នកដឹកនាំទុកគំរោងទាំងនោះមួយច្បាប់ ដើម្បីពិនិត្យមើល នៅពេលធ្វើរបាយការណ៍នៅអាទិត្យបន្ទាប់ ។

៦- ពិធីកាច់នំបុ័ង

៧- ការបិទកម្មវិធី ដោយច្រៀង និង អធិស្ឋាន ។

របៀបវារៈសំរាប់ការប្រជុំរបស់ក្រុមតូច

របៀបវារៈ និង ចំណងជើងផ្នែកនិមួយៗអាចផ្លាស់ប្តូរបាន ។ សូមតម្រូវរបៀបវារៈនេះ និង ចំណងជើងទាំងនេះអោយត្រូវទៅតាមកាលៈទេសៈ និង របៀបរបបរបស់ក្រុមជំនុំអ្នក ។

១- ការបើកកម្មវិធី

អធិស្ឋាន និង ច្រៀងសរសើរតម្កើង ។

២- រចាយការណ៍

សមាជិកក្រុមតូចធ្វើរបាយការណ៍អំពីកិច្ចការបំរើ ដែលពួកគេបានបំពេញ ហើយនិងចែកចាយទៅវិញទៅមកពីសំណូមពរអធិស្ឋានផងដែរ ។

៣- ការអធិស្ឋាន និង ការគិតគូរចំពោះគ្នាទៅវិញទៅមក

បើសិនជាក្រុមមានសមាជិកច្រើន សូមបំបែកជាក្រុមតូចៗដែលក្រុមនិមួយៗមានសមាជិកពីពីរទៅប្រាំមួយនាក់ ដើម្បីអធិស្ឋាន។ ត្រូវធ្វើការអធិស្ឋានតាមសំណូមពររបស់ម្នាក់ៗ និង សំរាប់អ្នកជំងឺ ។ នៅក្នុងពេលនោះអាចផ្តល់ជំបូន្មានឱ្យអ្នក ដែលមានបញ្ហាដែរ ។

គោលដៅនៃការឃ្វាល

- បង្រៀនអ័ំសុមាលី ដែលចូលរួមក្នុងក្រុមតូចនោះ អោយចេះផ្តល់ជំបូន្មានដល់ស្ត្រី ជួយក្រុមគ្រួសាររបស់ពួឈុនឱ្យជានានឹងគ្នាវិញ និង ជួយណែនាំលោកតាមករាអោយអាចឈប់ប្រមឹកស្រា ។
- បង្ហាត់បង្រៀនសមាជិកក្នុងក្រុមតូចនោះ អោយចេះផ្តល់ជំបូន្មានដល់អ្នកដទៃ ។

ដោយសារលោកសុខបានធ្វើតាមរបៀបនេះ ទើបក្រុមតូចមួយបានកើតឡើង ដោយសារទឹកចិត្តពុះពោររបស់គាត់ ហើយក្រុមតូចនេះនឹងរីកធំឡើងៗ រហូតដល់ក្លាយជាក្រុមតាមផ្ទះថ្មីមួយ ដែលជាក្រុមជំនុំតូចមួយរបស់ក្រុមជំនុំម្តាយ ។

ឥឡូវនេះ យើងនឹងរៀបរាប់អំពីគោលការណ៍សំខាន់ៗ និង ចំណុចសំខាន់ៗ ដែលធ្វើអោយយើងអាចយល់ពីមូលហេតុ ដែលនាំឱ្យក្រុមតូចនេះរីកចំរើន ។

គោលការណ៍សំខាន់ៗ



អ្នកដឹកនាំដែលមានសមត្ថភាព

លោកសុខបានចាប់ផ្តើមផ្សាយដំណឹងល្អ ដោយទឹកចិត្តពុះពារ និង ស្មោះត្រង់ ។ បន្ទាប់មក ដោយមានការណែនាំដ៏ឈ្លាសវៃ របស់គ្រូគង្វាលគាត់ លោកសុខបានបង្ហាញអោយឃើញថា គាត់ ជាមនុស្សខិតខំធ្វើការងារ ចេះដាក់ខ្លួន និង មានសមត្ថភាពធ្វើ ការងារ ។

គ្រូគង្វាល : (បើសិនជាអ្នកដឹកនាំថ្មីបានបង្កើតក្រុមតូចរួច ហើយ សូមថាដូចនេះ) : បងប្អូនដែលជាសមាជិកក្រុមតូច តើបងប្អូនសន្យាថានឹងរួមសហការជាមួយគាត់ ដើម្បីបំពេញកិច្ចការបំរើរបស់ក្រុម ដោយប្រតិបត្តិតាមព្រះបន្ទូលព្រះ-ជាម្ចាស់ ដែលគាត់នឹងបង្រៀនបងប្អូន ហើយសហការជាមួយគ្នា ដោយសេចក្តីស្រឡាញ់ ដើម្បីបំពេញភារៈកិច្ចរៀងៗខ្លួនដែរឬទេ ?

សមាជិករបស់
ក្រុមតូច : យើងខ្ញុំនឹងធ្វើដូចនេះ ដោយមានព្រះជាម្ចាស់ជួយ ។

អធិស្ឋានសំរាប់អ្នកដឹកនាំថ្មី និង ក្រុមតូចរបស់គាត់ ហើយថ្វាយសមាជិកក្រុមតូច អ្នកដឹកនាំក្រុមតូច កិច្ចការបំរើ និង ការរីកចំរើនរបស់ក្រុមតូចទៅព្រះអម្ចាស់ ។ (បើសិនជាក្រុមជំនុំអ្នកធ្លាប់អធិស្ឋានដាក់ដៃ សូមអធិស្ឋានដាក់ដៃលើអ្នកដឹកនាំថ្មី) ។

គ្រូគង្វាល : តើអ្នកនឹងបង្ហាត់បង្រៀនអ្នកជឿផ្សេងទៀត ដែលមានសមត្ថភាព ឱ្យក្លាយជាអ្នកដឹកនាំជំនួយ ដើម្បីឱ្យពួកគេអាចនឹងចូលរួមបំពេញភារៈកិច្ចក្នុងក្រុមជាមួយអ្នក និង ដឹកនាំក្រុមរបស់ពួកគេផ្ទាល់ នៅពេលអនាគតដែរឬទេ ?

អ្នកដឹកនាំថ្មី : ខ្ញុំនឹងធ្វើដូចនេះ ដោយមានព្រះជាម្ចាស់ជួយ ។

គ្រូគង្វាល : (សួរសំណួរនេះ ទៅក្រុមជំនុំ) បងប្អូនសមាជិកក្រុមជំនុំ តើបងប្អូននឹងគាំទ្រ (ឈ្មោះអ្នកដឹកនាំថ្មី) ក្នុងការបំពេញកិច្ចការរបស់គាត់ និងអធិស្ឋានសំរាប់គាត់ជាប់ជានិច្ចដែរឬទេ ?

សមាជិកក្រុមជំនុំ : យើងខ្ញុំនឹងធ្វើដូចនេះ ដោយមានព្រះជាម្ចាស់ជួយ ។

ការរីកចំរើនដោយខ្លួនឯងតាមធម្មតា

ក្រុមរបស់លោកសុខកើតឡើង ដោយសារគាត់បង្កើតទំនាក់ទំនងល្អជាមួយមនុស្ស ។ ឯអ្នកទាំងនោះ បានទទួលសេចក្តីស្រឡាញ់ សេចក្តីសង្ឃឹម និង ការលើកទឹកចិត្តពីគាត់ ។ ដូច្នេះក្រុមតូចនេះមិនមែនកើតឡើងដោយសារការបង្ខំមនុស្សអោយចូលរួម ឬ ក្រិត្យក្រមច្បាប់ទំលាប់ ឬ តាមការនឹកឃើញភ្លាមៗរបស់នរណាម្នាក់នោះទេ ។

គោលដៅច្បាស់លាស់

ក្រុមរបស់លោកសុខរៀបចំគោលបំណង និង គោលដៅផ្សេងៗ តម្រូវទៅតាមសេចក្តីត្រូវការ ។ ប៉ុន្តែ គោលដៅសំខាន់បំផុតរបស់ក្រុមតូចនេះ គឺផ្សាយដំណឹងល្អ និង ថែរក្សាគ្នាទៅវិញទៅមកដោយសេចក្តីស្រឡាញ់ ។

កិច្ចការឃ្វាលដែលសហការគ្នា

កិច្ចការល្អមួយរបស់ការងារលោកសុខ គឺគាត់ និង ក្រុមរបស់គាត់មានទំនាក់ទំនងល្អជាមួយក្រុមជំនុំម្តាយ និង គ្រូគង្វាលរបស់ក្រុមជំនុំនោះដែរ ។ ក្រុមជំនុំម្តាយ និង គ្រូគង្វាលមិនចាត់ទុកថាលោកសុខជាគូប្រជែងទេ តែពួកគេទាំងអស់គ្នាលើកទឹកចិត្តគាត់ និងបង្រៀនគាត់អោយចេះធ្វើការងារ ដែលមានលទ្ធផលកាន់តែល្អទៅវិញ ។

កិច្ចការបំរើផ្សេងៗទៀត ដែលក្រុមតូចក្នុងក្រុមជំនុំអាចធ្វើ

ក្រុមតូចទាំងនេះ ភាគច្រើនមានលក្ខណៈដូចនឹងក្រុមតូចរបស់លោកសុខដែរ គឺមានមុខនាទីឃ្វាល និង ផ្សាយដំណឹងល្អ ។ ក្រុមតូចក៏អាចបង្កើតឡើងសំរាប់បំពេញកិច្ចការបំរើណាមួយ ឬ គោលដៅពិសេសណាមួយផ្សេងទៀតដែរ ។ មានកិច្ចការបំរើច្រើនណាស់ ដែលក្រុមតូចនៅក្នុងក្រុមជំនុំអាចធ្វើ ។

ក្រុមជំនុំម្តាយ



គ្រូគង្វាល : តើអ្នកនឹងទទួលការត្រួតពិនិត្យរបស់គ្រូគង្វាល និង របស់ក្រុមជំនុំអ្នក ក្នុងការបំពេញមុខងារបំរើនេះ ដោយស្ថិតនៅក្រោមការដឹកនាំរបស់គ្រូគង្វាល និង ក្រុមជំនុំដែរឬទេ ?

អ្នកដឹកនាំថ្មី : ខ្ញុំនឹងទទួល ដោយមានព្រះជាម្ចាស់ជួយ ។

គ្រូគង្វាល : តើអ្នកនឹងអធិស្ឋានទៀងទាត់ សំរាប់សមាជិកម្នាក់ៗរបស់ក្រុមអ្នក និង ទុកពេលសំរាប់ផ្តល់ដំបូន្មានអោយសមាជិកម្នាក់ៗ ដើម្បីកសាងគេអោយជឹរកឡើងខាងព្រលឹងវិញ្ញាណដែរឬទេ ?

អ្នកដឹកនាំថ្មី : ខ្ញុំនឹងធ្វើដូចនេះ ដោយមានព្រះជាម្ចាស់ជួយ ។

គ្រូគង្វាល : តើអ្នកនឹងណែនាំសមាជិករបស់ក្រុមអ្នកគ្រប់គ្នា អោយធ្វើកិច្ចការបំរើខ្លះ ដើម្បីកសាង និង ជាស់គ្នៀនអ្នកឯទៀតដែរឬទេ ?

អ្នកដឹកនាំថ្មី : ខ្ញុំនឹងធ្វើដូចនេះ ដោយមានព្រះជាម្ចាស់ជួយ ។

បទព្រះគម្ពីរល្អ។សំរាប់ទទួលស្គាល់អ្នកដឹកនាំថ្មី គឺ អេសេគីអែល ៣៤:១-១៦ និង ទីតុស ១:៥-៩ ។

គ្រូគង្វាល : (សួរសំណួរទាំងនេះ ទៅអ្នកដឹកនាំថ្មី ដែលឈរនៅពីមុខក្រុមជំនុំ) ។ តើអ្នកសន្យាថា ដោយមានព្រះជាម្ចាស់ជួយ អ្នកនឹងធ្វើអោយ ចរិយាមារយាទជាគ្រីស្តជនរបស់អ្នក និង សេចក្តីបង្រៀនអំពីព្រះគម្ពីររបស់អ្នក ក្លាយជាគំរូសំរាប់សមាជិករបស់ក្រុមតូចរបស់អ្នកដែរឬទេ ?

អ្នកដឹកនាំថ្មី : ខ្ញុំសន្យា ដោយមានព្រះជាម្ចាស់ជួយ ។

គ្រូគង្វាល : តើអ្នកនឹងប្រតិបត្តិតាមព្រះបន្ទូលព្រះជាម្ចាស់ ដោយពឹងលើឫទ្ធានុភាព និង ការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបំពេញកិច្ចការឃ្វាលនេះដែរឬទេ ?

អ្នកដឹកនាំថ្មី : ខ្ញុំនឹងប្រតិបត្តិតាម ដោយមានព្រះជាម្ចាស់ជួយ ។

នៅក្នុងចំណោមកិច្ចការខាងក្រោមនេះ សូមគូសសញ្ញាសំគាល់នៅពីមុខកិច្ចការបំរើ ដែលក្រុមជំនុំអ្នកត្រូវការ (គូសចំនួនប៉ុន្មានក៏បាន) :

☐ ក្រុម**ផ្សាយដំណឹងល្អ** ។

☐ ក្រុមសំរាប់**មនុស្សនៅលីវ** សំរាប់ដោះស្រាយសេចក្តីត្រូវការរបស់អ្នកទាំងនោះ ។

☐ ក្រុមដែលមានសមាជិក**មកពីកន្លែងតែមួយ** ឬ មានមុខរបរតែមួយ ឬ មានអាយុដូចគ្នា ឬ មានចំណូលចិត្តប្រហាក់ប្រហែលគ្នា សំរាប់ផ្សាយដំណឹងល្អ និង បង្កើតសាវ័កក្នុងចំណោមមនុស្ស ដែលសមាជិកក្រុមនោះធ្លាប់ស្គាល់ ។

☐ ក្រុមសំរាប់កសាង ស្តារជីវិតពួក**អ្នកប្រមឹកស្រា** ឬ **ញៀនគ្រឿងញៀន**ឡើងវិញ ។

☐ ក្រុមសំរាប់**អ្នកជំនាញ** ឬក៏សំរាប់**និស្សិត** ។

☐ ក្រុមសំរាប់**ជនជាតិភាគតិច** ដែលមានវប្បធម៌ផ្សេង ។

☐ ក្រុមសំរាប់ធ្វើកិច្ច**ការបំរើមនុស្សខ្វាក់ មនុស្សថ្លង់ ឬ ពួកអ្នកដែលពិការ** (ខាងរូបកាយ ឬ ខាងផ្លូវចិត្ត ឬ ខាងសតិអារម្មណ៍) ។

- ☐ ក្រុមដែលសំដែង**ល្ខោនដកស្រង់ពីព្រះគម្ពីរ** សំរាប់ផ្សាយដំណឹងល្អ ឬ កសាងក្រុមជំនុំអោយរីកចំរើនឡើង ។
- ☐ ក្រុមសំរាប់បំពេញ**ការងារសង្គមកិច្ច** ។
- ☐ ក្រុមដែលថ្វាយខ្លួនធ្វើការអធិស្ឋានខ្លាំងក្លា និង **អធិស្ឋានពិសេស** ។
- ☐ ក្រុមសំរាប់ពួកអ្នក ដែល**កាន់ទុក្ខមរណៈភាព**របស់ពួកអ្នកដែលគេស្រឡាញ់ ។
- ☐ ក្រុមរបស់មនុស្ស ដែលមាន**បញ្ហាប្រហាក់ប្រហែលគ្នា** ។
- ☐ ក្រុមសំរាប់**ប្តីប្រពន្ធទើបនឹងរៀបការថ្មី** ដើម្បីសិក្សាអំពីកិច្ច-ការ ដែលទាក់ទងនឹងជីវិតប្តីប្រពន្ធ និង ការរៀបចំគ្រួសារថ្មី និង ជីវិតរស់នៅរួមគ្នា ។
- ☐ ក្រុមសំរាប់**អ្នកជឿថ្មី** ដែលត្រូវជួយឱ្យរីកចំរើនក្នុងជំនឿ ។
- ☐ ក្រុមរបស់**គ្រីស្តជនតន្ត្រីករ** ដើម្បីហាត់រៀនលេងឧបករណ៍តន្ត្រី ឬ ច្រៀង ។
- ☐ ក្រុមធ្វើកិច្ចការបំរើ**មនុស្សចាស់ដែល**នៅម្នាក់ឯង ឬ ពិការ ។

ដឹកនាំក្រុមតូច ជាការទទួលខុសត្រូវធំណាស់ ដូច្នេះគួរតែធ្វើការចាត់តាំងអ្នកបំពេញកិច្ចការបំរើនេះ ជាផ្លូវការនៅចំពោះមុខក្រុមជំនុំទាំងមូល ទើបជាការល្អ ។ នេះជាឧទាហរណ៍មួយ អំពីពិធីខ្លីមួយ ដែលអាចធ្វើក្នុងការប្រជុំថ្វាយបង្គំ ។



ការទទួលស្គាល់ និង ការប្តេជ្ញាបំពេញកិច្ចការបំរើរបស់អ្នកដឹកនាំថ្មីរបស់ក្រុមតូច

មុននឹងបំពេញតួនាទីរបស់ខ្លួន អ្នកដឹកនាំថ្មីត្រូវសន្យានៅចំពោះព្រះជាម្ចាស់ និង សមាជិកទាំងឡាយថា នឹងបំពេញភារៈកិច្ចរបស់ខ្លួន ។ សំណួរទាំងប៉ុន្មាននៅទំព័របន្ទាប់នេះ អាចយកទៅប្រើបាន ឬក៏អ្នកអាចបង្កើតពាក្យពេចន៍ សំរាប់អោយអ្នកដឹកនាំក្រុមតូចថ្មីនិយាយបញ្ជាក់ពីការប្តេជ្ញាចិត្តបាន ។

- ត្រូវយកចិត្តទុកដាក់ចំពោះទំនាក់ទំនងរវាងបុគ្គល ។ សូមកុំទុកអោយសមាជិកមានទំនាស់ជាមួយគ្នាយូរពេក ហើយត្រូវធ្វើយ៉ាងណាអោយសមាជិកដែលទាស់គ្នា បានជានានឹងគ្នាវិញ ។
- ធ្វើយ៉ាងណាអោយគ្រួសារទាំងមូលៗ ចូលរួមចំណែកក្នុងក្រុមតូច ។
- សូមប្រារព្ធធ្វើកម្មវិធីពិសេសៗ ដែលទាក់ទងនឹងក្រុមគ្រួសាររបស់សមាជិកក្រុម ។
- បើអាចធ្វើបាន ត្រូវបែងចែកភារៈកិច្ចឱ្យសមាជិកក្រុមបំពេញព្រមទាំងបណ្តុះបណ្តាលអ្នកទាំងនោះ ឱ្យចេះបំពេញភារៈកិច្ចនោះ ។ ការដែលប្រសើរបំផុត គឺបង្រៀនអោយសមាជិកខ្លះចេះដឹកនាំក្រុមរបស់ពួកគេផ្ទាល់ ។ ធ្វើដូចនេះ ក្រុមជំនុំនឹងរីកធំឡើងយ៉ាងមានសណ្តាប់ធ្នាប់ ។

- ☐ ក្រុមអធិស្ឋានសំរាប់**បេសកកម្មនៅបរទេស** និង រករបៀបចាត់សាសនទូតទៅកាន់កន្លែង ដែលមិនទាន់ញ្ជដំណឹងល្អ ។
- ☐ ក្រុមទៅសួរសុខទុក្ខ**អ្នកជំងឺ**នៅតាមផ្ទះ ឬ តាមមន្ទីរពេទ្យ ។
- ☐ ក្រុមទៅសួរសុខទុក្ខតាម**មណ្ឌលកុមារកំព្រា** ។
- ☐ ក្រុម**បង្កើតក្រុមជំនុំសាខាថ្មី** ។
- ☐ ក្រុម**ផ្តល់ដំបូន្មាន** ដើម្បីជួយមនុស្សដែលមានបញ្ហា ។

ក្នុងចំណោមកិច្ចការបំរើទាំងប៉ុន្មាន ដែលអ្នកទើបនឹងបានគូសសំគាល់សញ្ញា តើកិច្ចការបំរើណាខ្លះ ដែលជាគោលដៅរបស់ក្រុមតូចទីមួយ ដែលអ្នកចង់បង្កើត ? (អ្នកអាចដាក់គោលដៅពីរ ឬ បីរួមជាមួយគ្នា) ។

_____

_____

_____

_____

_____

សូមចាំជានិច្ចថា ក្រុមតូចត្រូវការ**អ្នកដឹកនាំដែលមានសមត្ថភាពការរីកចំរើនដោយខ្លួនឯងតាមធម្មតា គោលបំណង និង គោលដៅច្បាស់លាស់** និង **កិច្ចការឃ្វាលដែលសហការគ្នា** ។ សូមគិតគូរអំពីក្រុមតូចតាមផ្ទះ ដែលនឹងត្រូវចាប់ផ្តើម នៅពេលក្រោយៗទៀត :

១- តើគោលដៅពិសេសរបស់ក្រុមនេះ គឺអ្វីខ្លះ ? ។

_____

_____

២- តើអ្នកណានឹងដឹកនាំក្រុមនេះ ? ។

_____

៣- តើអ្នកណាបង្រៀន និង ពិនិត្យមើលអ្នកដឹកនាំ ? ។

_____

៤- តើក្រុមតូចមានគោលដៅសំខាន់អ្វីផ្សេងទៀត ? ។

_____

_____

_____

- មិនត្រូវជួបប្រជុំគ្នានៅក្នុងក្រុមតូច ដើម្បីថ្វាយបង្គំផង និងធ្វើសកម្មភាពកំសាន្តបញ្ចូលជាមួយគ្នាផងនោះទេ ។ បានន័យថា ត្រូវមានការជួបជុំគ្នា ដើម្បីថ្វាយបង្គំ អធិស្ឋាន និង អានព្រះគម្ពីរជាមួយគ្នា ហើយនៅពេលផ្សេង សមាជិកអាចជួបជុំគ្នា ដើម្បីបរិភោគចំណីអាហារជាមួយគ្នា លេងល្បែងកំសាន្តជាមួយគ្នា ឬ សំរាកកំសាន្តជាមួយគ្នា ។
- មិនត្រូវទុកឱ្យសមាជិកនិយាយពីកិច្ចការជំនួញ ឬ ពីនយោបាយក្នុងពេលជួបជុំក្រុមតូចឡើយ ។ សូមកុំយកពេលប្រជុំនេះ ដើម្បីពិភាក្សាពីកំហុសអ្នកដែលមិនបានមកចូលរួមឡើយ ។ សូមតម្រង់ការងាររបស់ក្រុមទៅតាមសកម្មភាពរបស់ព្រះគម្ពីរ ។ ក្រុមខ្លះធ្វើពីកាច់នំបុ័ងជាមួយគ្នា ។
- ធ្វើយ៉ាងណាអោយក្រុមអាចយកចិត្តទុកដាក់គិតគូរពីសេចក្តីត្រូវការរបស់មនុស្សគ្រប់គ្នា ដែលមកចូលរួមប្រជុំក្នុងក្រុមតូច និង ណែនាំជំរុញអោយពួកគេបំពេញកិច្ចការបំរើខ្លះ ។

© Project WorldReach © SEAN

- នៅក្នុងក្រុមតូច មិនត្រូវអធិប្បាយដូចក្នុងក្រុមជំនុំធំទេ ។ គោលបំណងរបស់ក្រុមតូច គឺអោយគ្រប់គ្នាបំពេញកិច្ចការបំរើខ្លះដែលជួយកសាងអ្នកឯទៀត ដូចជាអធិស្ឋាន ជាស់តឿន កំសាន្តចិត្ត ផ្តល់ដំបូន្មាន ប្រៀនប្រដៅកែតម្រង់ បង្រៀន ឬ ជួយដោយរបៀបផ្សេងៗទៀត ។ សូមអនុញ្ញាតិអោយសមាជិកពិភាក្សាគ្នា គឺជួនកាលមានមនុស្សពីរ ឬ បីនាក់ជជែកគ្នា ដែលជាឱកាសល្អសំរាប់កំសាន្តចិត្តគ្នា ។ សូមកុំបង្ខំភ្ញៀវដែលអៀនប្រៀនអោយនិយាយ ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអោយក្រុមរបស់អ្នក អាចឃ្វាលសមាជិកបានពេញលេញ តាមរបៀបនេះ ។

- មិនត្រូវអោយអ្នកអធិប្បាយមកពីក្រៅ ដែលយើងមិនស្គាល់ឬក៏ដែលចាត់ទុកខ្លួនឯងជាគ្រូអធិប្បាយ មានឥទ្ធិពលលើក្រុមនោះឡើយ ។ ព្រោះមិនខ្វះទេ មនុស្សដែលចង់បានមូលដ្ឋានមួយសំរាប់ពង្រឹងគំនិតរបស់ខ្លួន ។ អ្នកដឹកនាំក្រុមតូច ត្រូវដឹកនាំការប្រជុំក្នុងក្រុមតូច ដោយចាំជានិច្ចអំពីការនេះ ។

ភារៈកិច្ចរបស់គ្រូគង្វាលនៃក្រុមជំនុំចំពោះអ្នកដឹកនាំក្រុមតូច

បើសិនជាគ្រូគង្វាល ឬ អ្នកចាស់ទុំរបស់ក្រុមជំនុំចង់ទទួលបានលទ្ធផលល្អ គេត្រូវរួមសហការជួយរៀបចំ និង បង្ហាត់បង្រៀនអ្នកដឹកនាំក្រុមតូច ។

បើសិនជាអ្នកជាគ្រូគង្វាល ឬ អ្នកចាស់ទុំរបស់ក្រុមជំនុំ សូមគូសសញ្ញា «✓» នេះ នៅពីមុខសកម្មភាពខាងក្រោមនេះ មួយចំនួនដែលអ្នកនឹងយកមកអនុវត្ត ដើម្បីនាំឱ្យក្រុមតូចនិមួយៗរីកចំរើនទាំងខាងព្រលឹងវិញ្ញាណ ទាំងខាងចំនួន និង ទាំងខាងការទទួលខុសត្រូវ ។

☐ អធិស្ឋានជាប់ជាប្រចាំសំរាប់អ្នកដឹកនាំក្រុមតូចទាំងអស់ ។

☐ សូមឱ្យអ្នកដឹកនាំថ្មីប្រកាសបញ្ជាក់ នៅចំពោះមុខគេឯងថាពួកគេប្តេជ្ញាបំពេញភារៈកិច្ចរបស់ខ្លួន ហើយអ្នកត្រូវអធិស្ឋានសំរាប់ពួកគេ ដើម្បីទូលសូមអោយព្រះជាម្ចាស់ជួយពួកគេអោយអាចបំពេញកិច្ចការបំរើរបស់ពួកគេបាន ។ អ្នកអាចដាក់ដៃអធិស្ឋានអោយពួកគេក៏បានដែរ ។

- ☐ ជួយអ្នកដឹកនាំរៀបចំគោលដៅ និង ធ្វើគំរោងផែនការសំរាប់ក្រុមតូចរបស់ពួកគេ និង វាយតម្លៃការរីកចំរើនរបស់ក្រុមតូចទាំងនោះ ។

- ☐ ផ្តល់ជូនកំរងសៀវភៅសិក្សាព្រះគម្ពីរ ដែលទាក់ទងនឹងសេចក្តីត្រូវការ និង កិច្ចការបំរើរបស់ក្រុមនិមួយៗ ហើយបង្ហាញពួកគេពីរបៀបប្រើកំរងសៀវភៅសិក្សាទាំងអស់នោះ ។

- ☐ រៀបចំវគ្គបង្ហាត់បង្រៀនពិសេស សំរាប់បណ្តុះបណ្តាលអ្នកដឹកនាំអោយចេះផ្តល់យោបល់ដល់មនុស្ស ដែលមានបញ្ហាផ្សេងៗ ។

- ☐ ជួយអ្នកដឹកនាំក្រុមតូច អោយអាចជំរុញសមាជិកទាំងអស់អោយចូលរួមជាអតិបរមាក្នុងពេលប្រជុំ និង ក្នុងកិច្ចការបំរើ ដោយសួរសំណួរអំពីការសិក្សា និង កិច្ចការបំរើ ហើយរៀបចំផែនការជាមួយគ្នា ។

ដំបូន្មានខ្លះ សំរាប់អ្នកដឹកនាំក្រុមតូចអនុវត្ត

- បើសិនជាអាចរកផ្ទះផ្សេង សំរាប់ឱ្យក្រុមតូចជួបជុំគ្នាបាន នោះក្រុមតូចមិនគួរជួបជុំគ្នា នៅផ្ទះរបស់អ្នកដឹកនាំទេ ។ ក្រុមតូចអាចប្តូរកន្លែងជួបជុំគ្នាពីផ្ទះមួយ ទៅផ្ទះមួយ ជាពិសេស នៅផ្ទះរបស់មិត្តភក្តិអ្នកដែលមិនទាន់ជឿ ដែលអញ្ជើញអ្នក ។

- ពេលជួបជុំគ្នា ត្រូវអង្គុយជារង្វង់មូល ដើម្បីស្រួលអោយសមាជិកទាំងអស់ចូលរួមចំណែក ។ ធ្វើដូចនេះ នាំអោយមានភាពជិតស្និទ្ធល្អណាស់ ។

  កំណត់ចំណាំ : ដើម្បីអាចមានយោបល់កាន់តែច្រើនអំពីការជួបជុំគ្នាជាក្រុមតូច សូមមើលក្នុងសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល ទី ១២ « ក្រុមជំនុំតាមផ្ទះ » ឡើងវិញ ។

- ការដែលល្អ គឺសមាជិកក្រុមតូចត្រូវដាក់ដង្វាយ ។ ក្រោយដែលក្រុមចាត់ចែងចំណាយសំរាប់កិច្ចការបំរើរបស់ខ្លួនហើយ ក្រុមត្រូវប្រគល់ដង្វាយជូនហេរញ្ញិករបស់ក្រុមជំនុំម្តាយ ។

- ☐ សូមអោយសមាជិកគ្រប់ៗគ្នារបស់ក្រុមតូច ជួយបំពេញគោលដៅសំខាន់ៗរបស់ក្រុម និង ប្តេជ្ញាចិត្តចូលរួមសហការក្នុងក្រុម ។ ក្រុមរបស់អ្នកក៏ត្រូវជួយក្រុមតូចផ្សេងទៀតដែលនៅខ្សោយផងដែរ ។
- ☐ រៀបចំផែនការដែលធ្វើអោយក្រុមតូចបង្កើតក្រុមតូចថ្មីទៀតជាបន្ត ។ អោយអ្នកដឹកនាំថ្មី ដែលអ្នកបានរៀបចំ អាចបំពេញការងារបង្កើតក្រុមតូចថ្មីៗទៀត ទៅតាមចំនួនរបស់សមាជិក ដែលមានចិត្តចង់ចូលរួមជាមួយ ។
- ☐ ជំរាបត្រួតងារ ឬ អ្នកចាស់ទុំអំពីការរីកចំរើននៃក្រុមតូចរបស់អ្នក (ដូចជាអ្នកដែលថ្វាយខ្លួន សកម្មភាពកំពុងអនុវត្ត លទ្ធផលដែលបានទទួល អ្នកជំនួយណាដែលកំពុងហាត់រៀន សមាជិកដែលចេញពីក្រុម យោបល់អំពីការចាត់ចែងក្រុមទាំងអស់ ដែលទាក់ទងនឹងក្រុមជំនុំម្តាយ និង បញ្ហាដែលត្រូវការជំនួយពិសេសជាងធម្មតា ។ល។...) ។
- ☐ ផ្តល់សៀវភៅមើល ឬ អត្ថបទគម្ពីរដល់សមាជិក តម្រូវទៅតាមសេចក្តីត្រូវការរបស់ពួកគេ ។

- ☐ បង្កើតក្រុមពិសេសមួយសំរាប់ពួកអ្នកជឿថ្មី ដើម្បីបង្រៀនពួកគេអោយក្លាយជាសាវ័ក ដែលចេះគោរពប្រតិបត្តិតាមព្រះគ្រីស្ត ។ ក្រុមតូចនេះ ផ្តល់ឱកាសអោយអ្នកដឹកនាំអាចដឹងពីសេចក្តីត្រូវការ និង អំណោយទានខាងព្រលឹងវិញ្ញាណរបស់ពួកអ្នកជឿថ្មី ។ ម៉្យាងទៀត ត្រូវរៀបចំអ្នកជឿថ្មីទាំងនោះ អោយអាចទៅចូលរួមជាមួយក្រុមតូចផ្សេងទៀត ។ អ្នកអាចប្រើក្លូនសៀវភៅទី ៧ «ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត » ។
- ☐ ជួយសមាជិកក្រុមជំនុំគ្រប់គ្នា ឱ្យអាចចូលរួមក្នុងក្រុមតូចដែលបំពេញសេចក្តីត្រូវការរបស់ពួកគេ និង ណែនាំជំរុញពួកគេអោយធ្វើកិច្ចការបំរើខ្លះថ្វាយព្រះជាម្ចាស់ ។
- ☐ ជួយសមាជិក ដែលត្រូវផ្លាស់ទីលំនៅទៅសង្កាត់មួយទៀត អោយអាចចាប់ផ្តើមក្រុមតូចមួយទៀតនៅទីនោះ ។
- ☐ ជួយអ្នកដឹកនាំក្រុមតូចម្នាក់ៗ អោយអាចរៀបចំធ្វើអោយក្រុមរបស់គេបង្កើតក្រុមថ្មីៗតៗគ្នា (ជាពិសេស ពេលដែលក្រុមដំបូងមានសមាជិកមនុស្សពេញវ័យ លើសពីដប់ប្លូនាក់) ។

ភារៈកិច្ចរបស់អ្នកដឹកនាំក្រុមតូច

សូមគូសសញ្ញា «✓» នេះ នៅពីមុខភារៈកិច្ចទាំងឡាយ ដែលអ្នកចាត់ទុកថា ជាភារៈកិច្ចសំខាន់បំផុត សំរាប់អោយពួកអ្នកដឹកនាំក្រុមតូចបំពេញ (ភារៈកិច្ចខ្លះ ឬ ភារៈកិច្ចទាំងអស់ក៏បាន) ។

- ☐ អធិស្ឋានជាប់ជាប្រចាំសំរាប់សមាជិកទាំងអស់របស់ក្រុមតូច និង បង្រៀនសមាជិកទាំងនោះអោយក្លាយជាសាវ័ក ដើម្បីអោយជំនឿរបស់គេក្នុងព្រះគ្រីស្តរីកចំរើនឡើង ។
- ☐ រៀបចំផែនការ និង ការប្រជុំ ដោយហ្មត់ចត់ ។
- ☐ ជួយសមាជិកម្នាក់ៗរបស់ក្រុមអោយមានមុខងារ ដែលជួយកសាងអ្នកដទៃ ស្របតាមអំណោយទានខាងព្រលឹងវិញ្ញាណរបស់គេ ។
- ☐ ជួយសមាជិកក្រុមតូចអោយមានការនិមិត្តឃើញ រៀបចំគោលដៅ និង ធ្វើគំរោងផែនការសំរាប់អនុវត្តសកម្មភាពទាំងឡាយ ។
- ☐ នៅក្នុងការប្រជុំលើកទីមួយរបស់ក្រុមតូច ត្រូវពន្យល់អោយច្បាស់ ពីគោលបំណងរបស់ក្រុម (គឺកិច្ចការបំរើ ដែលពួកគេត្រូវបំពេញ និង លទ្ធផលដែលពួកគេចង់បាន) ។

- ☐ បើសិនជាក្រុមតូចលែងរីកចំរើន ត្រូវរៀបចំក្រុមតូចទាំងនោះឡើងវិញ ដើម្បីឱ្យសមាជិកអាចចូលទៅក្នុងក្រុមផ្សេងៗទៀត ឬក៏ត្រូវចាប់ផ្តើមក្រុមតូចជាថ្មី ដោយបំពេញកិច្ចការបំរើថ្មីទៀត ជ្រើសរើសអ្នកដឹកនាំថ្មី ឬ រៀបចំគោលដៅថ្មី ។
- ☐ ជួយអ្នកដឹកនាំម្នាក់ៗ អោយបង្ហាត់បង្រៀនអ្នកជំនួយម្នាក់ ឬពីរនាក់ ដែលនឹងបង្កើតក្រុមតូចផ្សេងទៀត នៅពេលក្រោយ ។
- ☐ ជួយពួកអ្នកដឹកនាំអោយបង្ហាត់បង្រៀនប្រធានបទ ដែលទាក់ទងទៅនឹងសេចក្តីត្រូវការរបស់សមាជិក ។

កំណត់ចំណាំ :